# < ករណីសិក្សាទី 3 >

# រឿងក្តីអនុបត្តប្រាតិភោគ

លោកមេធាវី អ៊ីវ ប៉ូលី
លោកមេធាវី SATO Naoshi
លោកមេធាវី YOSHIZAWA Toshiyuki
លោកស្រីសាស្ត្រាចារ្យ SUZUKI Ichiko

# ករណីសិក្សា

នៅថ្ងៃទី1 ខែមិថុនា ឆ្នាំ2014 អ្នកឲ្យខ្ចី Khiev Art(K) បានចុះកិច្ចសន្យាខ្ចីប្រាក់តាមខ្លឹមសារខាងក្រោមជាមួយអ្នកខ្ចីឈ្មោះ Sok Bora(S) ហើយបានប្រគល់ប្រាក់ចំនួន 80.000$។

ប្រាក់ដើម : 80.000$

ពេលកំណត់សង : ថ្ងៃទី 1 ខែមិថុនា ឆ្នាំ 2016

ការប្រាក់ : 10% ក្នុងមួយឆ្នាំ

ការប្រាក់យឺតយ៉ាវ : 20%ក្នុងមួយឆ្នាំ

នៅពេលចុះកិច្ចសន្យាខ្ចីបរិភោគប្រាក់នេះ K និង S បានព្រមព្រៀងគ្នាបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុ L ដែលមានទីតាំងនៅខេត្តឧត្តរមានជ័យ(ដីមិនទាន់ចុះបញ្ជី) ដោយ S មានប័ណ្ណបញ្ជាក់សិទ្ធិកាន់កាប់(ប្លង់ទន់)ហើយបានចុះលិខិតកិច្ចសន្យាខ្ចីប្រាក់ និង កិច្ចសន្យាបង្កើតហ៊ីប៉ូតែកជាលិខិតឯកជន (មិនបានចុះបញ្ជីហ៊ីប៉ូតែក ឬ ចុះបញ្ជីអំពីការដាក់ធានា(Gage)លើដីនោះទេ)។

ប៉ុន្តែ K បានអះអាងថា S មិនបង់ប្រាក់ដើម និងការប្រាក់ ដោយស្ម័គ្រចិត្តនោះទេ ទោះបីជាពេលកំណត់សងបានកន្លងផុតក៏ដោយ ហើយ K បានអនុវត្តហ៊ីប៉ូតែកលើអចលនវត្ថុ L នោះ។

ផ្ទុយពីនេះ S បានអះអាងថា ខ្លួនបានសងប្រាក់ចំនួន 60.000$ ឲ្យទៅ K រួចហើយ ហើយ K បានបង្ហាញឆន្ទៈលើកលែងប្រាក់ដើម និងការប្រាក់ដែលនៅសល់ទៅកាន់ S ។

# ករណីសិក្សា (គំនូស)

អ្នកឲ្យខ្ចី Khiev Art (K)



80,000$

អ្នកខ្ចី Sok Bora (S)





កិច្ចសន្យាខ្ចីប្រាក់ និង កិច្ចសន្យាបង្កើតហ៊ីប៉ូតែក

- ប្រាក់ដើម : 80,000$
- ពេលកំណត់សង : ថ្ងៃទី1 ខែមិថុនា ឆ្នាំ2016
- ការប្រាក់ : 10% ក្នុងមួយឆ្នាំ
- ការប្រាក់យឺតយ៉ាវ : 20% ក្នុងមួយឆ្នាំ
- បង្កើតហ៊ីប៉ូតែកលើដី L ដែលមិនទាន់ចុះបញ្ជី

អចលនវត្ថុ L ដែលមិនទាន់ចុះបញ្ជី



លិខិតឯកជន

ការបង្កើតហ៊ីប៉ូតែក( គ្មានការចុះបញ្ជីហ៊ីប៉ូតែក និង ចុះបញ្ជី Gage)

ប្លង់ទន់

ការប្រគល់ប្លង់ទន់ ?

# ករណីសិក្សា（គំនូស）

អ្នកឲ្យខ្ចី K



ទោះបីជាថ្ងៃកំណត់សងបានកន្លងផុតក៏ដោយ ក៏ S មិនបានសងប្រាក់ដើម និង ការប្រាក់ដោយស្ម័គ្រចិត្តទេ។

ការអនុវត្តហ៊ីប៉ូតែក

ប្លង់ទន់

អ្នកខ្ចី S

អចលនវត្ថុ L ដែលមិនទាន់ចុះបញ្ជី





① ថ្ងៃទី1 ខែមិថុនា ឆ្នាំ2016 បានសង 60.000$ ឲ្យទៅ K

② ចំពោះប្រាក់ដើមដែល និងការប្រាក់ដែលនៅសល់ K បានបង្ហាញឆន្ទៈថាលើកលែងទៅកាន់ S។

## សំណួរទី1 តើហ៊ីប៉ូតែកបានបង្កើតលើអចលនវត្ថុ L ដែរឬទេ ?

ចំពោះកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ទម្រង់មិនមានភាពចាំបាច់ទេ កិច្ចសន្យាអាចបង្កើតតាមការព្រមព្រៀងរបស់គូភាគីបាន (ក្រមរដ្ឋប្បវេណីមាត្រា 844 ) ហេតុនេះ កិច្ចសន្យាបង្កើតហ៊ីប៉ូតែករវាង K និង S មានអានុភាព។

ប៉ុន្តែ បើសិនជាមិនបានធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែកជាលិខិតយថាភូត និងមិនបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីទេ មិនអាចតតាំងចំពោះតតិយជនឡើយ (ក្រមរដ្ឋប្បវេណីមាត្រា 845) ហេតុនេះ នៅពេលដែលមានការរឹបអូសដោយតតិយជនទាំងស្ថានភាពបែបនេះ ហ៊ីប៉ូតែករបស់ K មិនអាចតតាំងចំពោះការរឹបអូសរបស់តតិយជនទេ។

**សំណួរទី** 1 (សំណួរពាក់ព័ន្ធ) ចំពោះប្រាតិភោគរវាង K និង S ក្នុងករណីដែលមិនមែនបង្កើតសិទ្ធិហ៊ីប៉ូតែក តែជាការបង្កើតសិទ្ធិលើការបញ្ចាំ (បញ្ចាំអចលនវត្ថុ) ហើយបានប្រគល់ប្លង់ទន់ (ប៉ុន្តែក្នុងករណីដែលទោះបីជាក្រោយពេលកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំក៏ដោយ ក៏ S បានកាន់កាប់ និងប្រើប្រាស់អចលនវត្ថុ L) តើត្រូវធ្វើដូចម្តេច?

ក្រៅពីការព្រមព្រៀងរវាងភាគី សិទ្ធិលើការបញ្ចាំបង្កើតឡើងផ្អែកតាមការប្រគល់វត្ថុដែលជាកម្មវត្ថុ(ការផ្ទេរការកាន់កាប់) (ក្រមរដ្ឋប្បវេណីមាត្រា 818 កថាខណ្ឌទី1 · លក្ខខណ្ឌបង្កើតសិទ្ធិលើការបញ្ចាំ)។ នៅក្នុងរឿងក្តីនេះ ដោយសារតែ S កំពុងកាន់កាប់ និង ប្រើប្រាស់អចលនវត្ថុ L ក្រោយកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ហេតុនេះ មិនមានការប្រគល់វត្ថុដែលជាកម្មវត្ថុទេ (ការផ្ទេរការកាន់កាប់)។ នៅក្នុងក្រមរដ្ឋប្បវេណីប្រទេសកម្ពុជា មិនទទួលស្គាល់ការបញ្ចាំដោយមិនផ្ទេរការកាន់កាប់ឡើយ។ ដូចនេះ កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំរវាង K និង S គ្មានអានុភាព។

យ៉ាងណាមិញ ក្នុងករណីដែល K បានកាន់កាប់អចលនវត្ថុ L ក្រោយការបង្កើតសិទ្ធិលើការបញ្ចាំ ការបញ្ចាំអចលនវត្ថុនឹងបង្កើតឡើងដោយមានអានុភាព។ ប៉ុន្តែ លក្ខខណ្ឌតតាំងចំពោះតតិយជនអំពីការបញ្ចាំអចលនវត្ថុ គឺជាការចុះបញ្ជីបង្កើតសិទ្ធិលើការបញ្ចាំ (ក្រមរដ្ឋប្បវេណីមាត្រា839 មាត្រា845) ហេតុនេះ មិនអាចធ្វើការចុះបញ្ជីដោយផ្អែកតាមការឲ្យ និងការទទួលប្លង់ទន់ដែលមិនធ្វើតាមការចុះបញ្ជីទេ ហើយសិទ្ធិលើការបញ្ចាំរបស់ K មិនអាចតតាំងចំពោះតតិយជនទេ។

# សំណួរទី1 (សំណួរពាក់ព័ន្ធ) តើចំណុចណាដែលត្រូវប្រុងប្រយ័ត្នតាមរយៈការបង្កើតអំពីប្រាតិភោគទាក់ទងនឹងដីដែលមិនបានចុះបញ្ជី?

## ការបង្កើតប្រាតិភោគទាក់ទងនឹងដីដែលមិនបានចុះបញ្ជី

ចំពោះភាគីដែលធ្វើការព្រមព្រៀងដាក់ប្រាតិភោគលើអចលនវត្ថុ ប្រាកដជាមានគោលបំណងប្រមូលនូវសិទ្ធិលើបំណុលអាទិភាពផ្អែកតាមច្បាប់ ពីអចលនវត្ថុប្រាតិភោគនៅពេលដែលមិនអនុវត្តកាតព្វកិច្ច។ ស្របតាមគោលបំណងនេះ ក្នុងករណីដែលដាក់ប្រាតិភោគលើអចលនវត្ថុដែលមិនបានចុះបញ្ជី ① បើសិនជាសល់នូវការកាន់កាប់វត្ថុដែលជាកម្មវត្ថុចំពោះកូនបំណុល (អ្នកបង្កើត) រហូតដល់ពេលអនុវត្តសិទ្ធិប្រាតិភោគហើយចុះកិច្ចសន្យាបង្កើតហ៊ីប៉ូតែក និង②បើសិនជាផ្ទេរនូវការកាន់កាប់វត្ថុដែលជាកម្មវត្ថុឲ្យទៅម្ចាស់បំណុល (ម្ចាស់សិទ្ធិប្រាតិភោគ) ហើយទទួលនូវការប្រគល់វត្ថុដែលជាកម្មវត្ថុដោយផ្អែកតាមការចុះកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ព្រមទាំង ក្រោយពេលបង្កើតសៀវភៅចុះបញ្ជីទាក់ទងនឹងអចលនវត្ថុប្រាតិភោគ នោះចំពោះករណីទី ① មានភាពចាំបាច់ក្នុងការចុះបញ្ជីបង្កើតហ៊ីប៉ូតែក និងក្នុងករណីទី ② មានភាពចាំបាច់ក្នុងការចុះបញ្ជីបង្កើតសិទ្ធិលើការបញ្ចាំដើម្បីសម្រេចនូវគោលបំណងនៃការព្រមព្រៀងរវាងភាគី។

# សំណួរទី 2

ចំពោះប្រាតិភោគ (ហ៊ីប៉ូតែក) ក្នុងករណីនេះ តើត្រូវអនុវត្តយ៉ាងដូចម្តេចខ្លះ?

ការអនុវត្តហ៊ីប៉ូតែកក្នុងករណីសិក្សានេះ តម្រូវឲ្យម្ចាស់បំណុលនៃហ៊ីប៉ូតែកដាក់ពាក្យបណ្តឹងអង្គសេចក្តីមកតុលាការ ដើម្បីទទួលបានសាលក្រមដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ (ហ៊ីប៉ូតែក ជាអាទិ៍)។ បន្ទាប់មកម្ចាស់បំណុលហ៊ីប៉ូតែកអាចដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែក ដោយភ្ជាប់ជាមួយឯកសារដូចខាងក្រោម ៖

- ទី1 ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត (CCP#496)
- ទី2 រូបមន្តអនុវត្ត (CCP#354)
- ទី3 លិខិតបញ្ជាក់អំពីការបញ្ជូន (CCP#360)
- ទី4 ឯកសារដែលបញ្ជាក់ថាអចលនវត្ថុនោះ ជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត

# សំណួរទី 3

បើសិនជា A ដែលជាម្ចាស់បំណុលផ្សេងរបស់ S បានរឹបអូសអចលនវត្ថុក្នុងករណីសិក្សានេះ តើ K អាចអះអាងអំពីសិទ្ធិណាមួយ (ហ៊ីប៉ូតែក ការដាក់ធានា និងសិទ្ធិកាន់កាប់ ជាអាទិ៍) ហើយអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបានដែរឬទេ?

# ករណីសិក្សានៃសំណួរទី 3（គំនូស）



**សំណួរទី3 បើសិនជា A ដែលជាម្ចាស់បំណុលផ្សេងរបស់ S បានរឹបអូសអចលនវត្ថុក្នុងករណីសិក្សានេះ តើ K អាចអះអាងអំពីសិទ្ធិណាមួយ (ហ៊ីប៉ូតែក ការដាក់ធានា និងសិទ្ធិកាន់កាប់ ជាអាទិ៍) ហើយអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបានដែរឬទេ?**

ក្នុងករណីសិទ្ធិដែល K បានបង្កើតជាសិទ្ធិហ៊ីប៉ូតែក នោះបណ្តឹងតវ៉ារបស់តតិយជនមិនត្រូវបានទទួលស្គាល់ទេ។

ពីព្រោះសិទ្ធិហ៊ីប៉ូតែក (ក្រមរដ្ឋប្បវេណីមាត្រា 843) ជាសិទ្ធិប្រាតិភោគដែលមិនផ្ទេរការកាន់កាប់ ហេតុនេះ វាមិនមែនជា "សិទ្ធិដែលការពារនូវការប្រគល់" ទេ។

ក្នុងករណីដែល K បានទទួលនូវការប្រគល់អចលនវត្ថុ L ហើយសិទ្ធិលើការបញ្ចាំបានបង្កើតឡើងដោយមានអានុភាព ហើយក្នុងករណីដែល K បានចុះបញ្ជីបង្កើតសិទ្ធិលើការបញ្ចាំមុនការរឹបអូសរបស់ A ទោះបីជាក្រោយការអនុវត្តរបស់ A ក៏ដោយក៏សិទ្ធិលើការបញ្ចាំរបស់ K នៅបន្តអត្ថិភាពដែរ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 431)។ ក្នុងករណីនេះ K នឹងទទួលបន្ត ហើយអាចកាន់កាប់ ប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុ L បាន ហេតុនេះបណ្តឹងតវ៉ារបស់តតិយជនមិនអាចដាក់បានទេ។